ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ១៧០/១៨ គ.ជ.ប.ជ.

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែឧសភា និងទិសដៅខែមិថុនា ឆ្នាំ២០១៨

### I. ស្ថានភាពទូទៅ

ក្នុងខែឧសភា ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេសលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ និងសកម្មភាពអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក៏មានស្ថានភាពមិនប្រក្រតី ប្រជាពលរដ្ឋយើងជាច្រើនបាន និងកំពុងលង់ក្នុងល្បិចកលនៃឧក្រិដ្ឋជន ដែលឆក់ឱកាសបោកបញ្ឆោតមនុស្សទាំងប្រុស ស្រី ក្មេងចាស់ ដើម្បីកេងប្រវ័ញ្ច រំលោភបំពានតាមគ្រប់មធ្យោបាយ ដោយអមនុស្សធម៌ និងគ្មានខ្លាចក្រែងរអែងច្បាប់។ បទល្មើសជាច្រើនត្រូវបានរកឃើញជាបន្តបន្ទាប់ តែបទល្មើសជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋដែលមានអង្គកាចាត់តាំង ប្រកបដោយល្បិចកលខ្ពស់ នាំមនុស្សឆ្លងដែនពីប្រទេសមួយ ទៅប្រទេសមួយទៀត ក្នុងគោលដៅកេងប្រវ័ញ្ច និងបានក្លាយ ជាទាសភាពសម័យទំនើប ដែលរំលោភបំពានលើសិទ្ធិ សេរីភាព និងអាយុជីវិតមនុស្សយ៉ាងធ្ងន់ធ្ងរ ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល បានខិតខំដោះស្រាយបញ្ហា និងភាពប្រឈមទាំងឡាយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ រាប់ទាំងការកសាងច្បាប់ គោលនយោបាយ លិខិតបទដ្ឋាន យន្តការ និងសេវាចាំបាច់ផ្សេងៗ ក្នុងនោះការផ្តល់ភាពស្របច្បាប់ជូនពលករប្រមានជាងមួយលាននាក់ ដែលបាន និងកំពុងធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ និងការបើកកន្លែងផ្តល់លិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតការងារ នៅទីតាំងសំខាន់ៗមួយចំនួន ហើយបានសហការយ៉ាងមមាញឹកជាមួយភាគីថៃ ដើម្បីផ្តល់ភាពស្របច្បាប់ដល់ពលករដែលនៅសេសសល់មួយចំនួនតូចឲ្យបានគ្រប់ៗគ្នា។ វាមានគុណប្រយោជន៍ខ្លាំងណាស់ ដែលជាដំណោះស្រាយមួយក្នុងការការពារពលករ ពីការរំលោភបំពាន និងកេងប្រវ័ញ្ច ក្នុងរូបភាពជាពលករខុសច្បាប់ ។ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើកិច្ចការជាច្រើនទៀត ដោយការប្រឹងប្រែងរួមគ្នា ជាមួយសហគមន៍អន្តរជាតិ និងប្រទេសពាក់ព័ន្ធ ដោយពង្រឹងកិច្ចសហការរវាងរាជរដ្ឋាភិបាល អង្គការដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីបង្កើតឱកាសការងារ និងខិតខំការពារសិទ្ធិរបស់ពលករកម្ពុជា ទាំងនៅក្នុង និងនៅក្រៅប្រទេស ដើម្បីឧត្តមប្រយោជន៍របស់ពលករ ពលការិនី និងក្រុមគ្រួសារទាំងអស់ និងខិតខំការពារប្រជាពលរដ្ឋ ពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាព។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបាន ៖

- ពីបណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានផ្តល់របាយការណ៍។
- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋាន២៤រាជធានី-ខេត្ត បានផ្តល់របាយការណ៍។ ដោយឡែកខេត្តស្វាយរៀង មិនបានផ្តល់របាយការមកលេខាធិការដ្ឋាន គ.ជ.ប.ជ។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០១៨ នេះ មានដូចខាងក្រោម៖

# ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

## ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

### ក.១-ច្បាប់ គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ៖

#### ក.១.១-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់៖
    - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
    - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.១.២-សន្ធិសញ្ញាកំពុងរៀបចំ៖

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
    - **ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"**
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
    - **ស្តីពី"បត្យាប័ន"**
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
    - **ស្តីពី "បញ្ជូនទណ្ឌិត"**
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.១.៣-**អនុស្សរណៈកំពុងរៀបចំ៖**

❖ **អនុស្សរណៈរវាងអង្គការដៃគូកំពុងរៀបចំ៖**

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការអន្តរជាតិ GVC ស្តីពីការគាំទ្រ និងការតស៊ូមតិលើសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា ក្នុងប្រទេសថៃ ដើម្បីទប់ស្កាត់ការរំលោភបំពានអំពើជួញដូរមនុស្ស។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

**ក.១.៤-បទដ្ឋានគតិយុត្ត កំពុងរៀបចំ៖**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**"។
- **ក្រសួងអប់រំ យុវជន និងកីឡា៖** ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

រដ្ឋបាលខេត្តចំនួន២ ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន៨.៥០៨ក្បាល (បាត់ដំបងចំនួន**៥.២៥៣**ក្បាល, បន្ទាយមានជ័យ**៣.២៥៥**ក្បាល) ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែឧសភា ឆ្នាំ២០១៨នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោលបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ដល់អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន៤.**៥២៣**លើក មានអ្នកចូលរួមសរុបចំនួន**៤៥៦.៣៧១**នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ**៣៧៥.១៨៧**នាក់) កើនឡើងចំនួន៨១.១៨៤នាក់ ស្មើនឹង**២១,៦៣%** ក្នុងនោះស្ត្រីមានចំនួន**២៦២.២៣១**នាក់។ (**ឧបសម្ព័ន្ធទី១**)

**ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន**

- **លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត** បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន៤២លើក (ខេត្តកោះកុង៣០លើក សៀមរាប១២លើក)។
- **ខេត្តបាត់ដំបង អង្គការ Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក៥៨នាក់ ស្រី២១នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស**

ខ.៤.១-<u>វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ៖</u>

- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការបង្ការ ទប់ស្កាត់សកម្មភាពពលករខ្មែរបម្រុងធ្វើចំណាកស្រុកខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃចំនួន០៣លើក មនុស្សចំនួន៨១នាក់ (ស្រី៣៣នាក់)។

**ខ.៤.២-<u>វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖</u>**

អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**២៧៤**គោលដៅ មានមនុស្សចំនួន**៩៣៩**នាក់ (ស្រី**៨៤៧**នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត៖** (តាកែវ កែប កំពង់ឆ្នាំង ស្វាយរៀង ស្ទឹងត្រែង និងឧត្តរមានជ័យ)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**២១**លើក ខេត្តអនុវត្តមាន៖ ស្វាយរៀង ឧត្តរមានជ័យ ស្ទឹងត្រែង និងព្រៃវែង។

**ខ.៥-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

ខ.៥.១-<u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន៣២២.៨៨៧នាក់ (ស្រី**១៤៧.៩១៦**នាក់) អនីតិជន**៧.៨៧៨**នាក់ (ស្រី**២.៩៧៨**នាក់) ក្នុងនោះស្របច្បាប់ចំនួន**១៨៣.៧៤៥**នាក់ (ស្រី**៩១.៤៩០**នាក់) អនីតិជន**៦១៩**នាក់ (ស្រី**២៥៣**នាក់) មិនស្របច្បាប់ចំនួន**១៣៩.១៤៤**នាក់ (ស្រី**៥៦.៤២៦**នាក់) អនីតិជន**៧.២៥៩**នាក់ (ស្រី**២.៧២៥**នាក់) បើប្រៀបធៀបនឹងខែមុនមានការកើនឡើងចំនួន**២២**នាក់ ស្មើនឹង**0.006%**។

## ខ.៥.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន**១៦០**លើក មនុស្សចំនួន**៤.៤៨០**នាក់ (ស្រី**១.៦០៨**នាក់ កុមារ**៤៥៨**នាក់)។ ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន**៣៦**លើក មនុស្ស**១១០**នាក់ ស្រី**៣៧**នាក់ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន**១២៤**លើក មនុស្ស**៤.៣៧០**នាក់ (ស្រី**១.៥៧១**នាក់ កុមារ**៤៥៨**នាក់)។

*ស្ថានភាព ៖*

- **ក្រុមការងារអនុវត្តច្បាប់**បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន**៥១**នាក់ (ស្រី**១២**នាក់) ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ចំនួន**៤.៩០៧**នាក់ ស្រី**១.៧២៧**នាក់ អនីតិជនចំនួន**៥៤៥**នាក់។
- **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញក្រោមរូបភាព "**និរទេស**" តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុប**៥៩**ជើង/រថយន្ត មានមនុស្សចំនួន**១.៩៥៧**នាក់ (ស្រី**៦៥៦**នាក់) ក្នុងនោះកុមារ**១៦១**នាក់ (កុមារី**៧២**នាក់)។ បើប្រៀបធៀប នឹងខែមេសា ឆ្នាំ២០១៨ គឺមានការថយចុះចំនួន**២.៣១១**នាក់ មូលហេតុផុតរយៈបុណ្យចូលឆ្នាំខ្មែរ។
  - ក្នុងចំនួនពលករខាងលើ ក្រោយពេលធ្វើសម្ភាសន៍រួច បានទទួលលទ្ធផលដូចខាងខាងក្រោម:
    - ពលករមួយចំនួនដែលមានថៅកែ ហើយចុះមកស្វែងរកក្រុមហ៊ុនធ្វើបែបបទស្របច្បាប់ មួយចំនួនមកទទួលវីសារស្របច្បាប់ពីក្រុមហ៊ុន មួយចំនួនផុតការអនុវត្តន៍ទោសពីពន្ធនាគារប្រទេសថៃ និងមួយចំនួនត្រឡប់មកលេងស្រុកកំណើតវិញ(ចូលរួមក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ)។
    - ពលកររួចផុតកំណត់ទោសនៅប្រទេសថៃចំនួន**៥១**នាក់ ស្រី**១២**នាក់
    - ពលករត្រឡប់មកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្នុងពេលបុណ្យចូលឆ្នាំខ្មែរ ចាប់ពីថ្ងៃ១៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ចំនួន**៣២.៤៨៥**នាក់ (ស្រី**១៥.០៥២**នាក់)។
- ដោយឡែក យោងរបាយការណ៍**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

  ១-ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន**៤៤**លើក មនុស្សចំនួន**១៣៧**នាក់ ស្រី**០៩**នាក់ មាន**៣៥**សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន២៨លើក មនុស្ស១០៧នាក់ ស្រី០៩នាក់ មាន២០សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេសតាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន១៦លើក មនុស្សចំនួន៣០នាក់ មាន១៥សញ្ជាតិ។

២-បទល្មើសស្នាក់នៅខុសច្បាប់ ៖

- ករណីលួចឆ្លងដែនខុសច្បាប់ មនុស្សចំនួន១១នាក់ ០២សញ្ជាតិ(វៀតណាម ១០នាក់ ថៃ០១នាក់)។
- ករណីស្នាក់នៅលើសទិដ្ឋាការ មនុស្សចំនួន០១នាក់ សញ្ជាតិអ៊ីតាលី។

៣-ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ៖

- សរុបមកដល់ពេលបច្ចុប្បន្នលទ្ធផលការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីពីជនបរទេសបែបអន្តោប្រវេសន៍សរុបចំនួន១.២០៨គ្រួសារ មនុស្សចំនួន៤.០៣៧នាក់ ស្រី១.៨៩៧នាក់ មាន០២សញ្ជាតិ(វៀតណាម និងថៃ)។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន១១៨គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរចំនួន១២នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន៩ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (រាជធានីភ្នំពេញ បាត់ដំបង កំពង់ចាម ក្រចេះ ព្រះវិហារ ស្វាយរៀង និងខេត្តត្បូងឃ្មុំ)។

### គ.១-ការងារអនុវត្តច្បាប់

#### គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១២/០៧ករណី (បើប្រៀបធៀបនឹងខែមុនកើនឡើង០៥ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន១៩នាក់ (ស្រី០៨នាក់) ក្នុងនោះជនបរទេសចំនួន០៦នាក់ (វៀតណាម០៣នាក់ និងចិន០៣នាក់)។ យើងបានសង្គ្រោះជនរងគ្រោះចំនួន២១នាក់ មានអាយុក្រោម១៥ឆ្នាំ០៧នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង១១នាក់ (ប្រគល់មន្ទីរសង្គមកិច្ច០៤នាក់ និងឲ្យគ្រួសារ១៧នាក់)។

### ១.អំពើជួញដូរមនុស្ស៖

បង្ក្រាបបាន**០៤/០១ករណី** (កើនឡើង០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០៩នាក់ (ស្រី០៥នាក់) ជនបរទេស០៣នាក់សញ្ជាតិចិន និងសង្គ្រោះជនរងគ្រោះចំនួន**១២**នាក់ មានអាយុ១៥-១៧ឆ្នាំ**០១**នាក់ និងអាយុ១៨ឆ្នាំឡើង**១១**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**០២**នាក់ និងឲ្យគ្រួសារ**១០**នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ<br>-ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២<br>០២ | ០៦<br>០៣ | ចិន០៣ |
| *សរុប* | *០៤* | *០៩* | *០៣* |

### ២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖

បង្ក្រាបបាន**០៨/០៦ករណី** (កើនឡើង០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន**១០**នាក់ ជនបរទេស**០៣**នាក់សញ្ជាតិវៀតណាម និងជនសង្ស័យជាអនីតិជន**០២**នាក់ សង្គ្រោះជនរងគ្រោះចំនួន**០៩**នាក់ មានអាយុក្រោម១៥ឆ្នាំ**០៧**នាក់ និងអាយុ១៥-១៧ឆ្នាំ**០២**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**០២**នាក់ និងឲ្យគ្រួសារ**០៧**នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ<br>-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២<br>០៦ | ០៤<br>០៦ | វៀតណាម០៣ |
| *សរុប* | *០៨* | *១០* | *០៣* |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

**ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ**

- យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការ IOM មានចំនួន**៥៩**នាក់ ស្រី**៤៦**នាក់ មកពី ៖

| | | |
|---|---|---|
| - ប្រទេសម៉ាឡេស៊ី | ចំនួន**២៥**នាក់ | (ស្រី**១៩**នាក់) |
| - ប្រទេសចិន | ចំនួន**១៨**នាក់ | (ស្រី**១៧**នាក់) |
| - ប្រទេសវៀតណាម | ចំនួន**០៦**នាក់ | (ស្រី**០៦**នាក់) |
| - ប្រទេសថៃ | ចំនួន**០៦**នាក់ | |
| - ប្រទេសសិង្ហបុរី | ចំនួន**០៣**នាក់ | (ស្រី**០៣**នាក់) |
| - ប្រទេសឡាវ | ចំនួន**០១**នាក់ | (ស្រី**០១**នាក់) |

*ស្ថាប័ន-អង្គភាពអនុវត្តមាន ៖*

- **អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់)** បានទទួលពលករខ្មែររងគ្រោះចំនួន១០នាក់(ស្រី) ក្នុងនោះមកពីប្រទេសវៀតណាម០៦នាក់ ចិន០៣នាក់ និងប្រទេសម៉ាឡេស៊ី០១នាក់ តាមការសម្ភាសបានឲ្យដឹងថាទៅតាមរយៈមេខ្យល់ទាំងអស់។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន១៧នាក់ (ស្រី១៤នាក់) និងកុមារី០៣នាក់)។ មានដូចខាងក្រោម៖

- បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន១៧នាក់ (ស្រី១៤នាក់ កុមារី០៣នាក់) ក្នុងនោះមកពី៖ ប្រទេសចិន១០នាក់ និងវៀតណាម០២នាក់ (ឆ្លងដែនទៅចិន) ក្នុងនោះមានករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ១៣នាក់ និងជួញដូរកម្លាំងពលកម្ម០៣នាក់ និងស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សជាជនជាតិវៀតណាម ០១នាក់ ដោយមានការសហការជាមួយអង្គការ សម្ព័ន្ធចាប់ដៃ អង្គAIM អង្គការរតនៈ និងអង្គការក្ដីសង្ឃឹមនិងយុត្តិធម៌។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលសាវតារបស់ជនរងគ្រោះចំនួន២៦នាក់ ពីប្រទេសដើម្បីស្វែងរកគ្រួសារមុនពេលធ្វើមាតុភូមិនិវត្តន៍ត្រឡប់ទៅស្រុកកំណើតវិញ។

**ឃ.៣-ការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅទទួលសេវាស្នាក់នៅ(រយៈពេលវែង-ខ្លី) និងស្ដារនីតិសម្បទា**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្ដារនីតិម្បទាចំនួន២១នាក់ (ស្រី១០នាក់, កុមារា១១នាក់) ក្នុងនោះមាន៖

- **មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ** បានធ្វើការពិគ្រោះយោបល់ និងបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៧នាក់ ទៅអង្គការដៃគូ។
- **អង្គការក្ដីសង្ឃឹម និងយុត្តិធម៌** បានផ្ដល់សេវាស្នាក់នៅរយៈពេលខ្លី និងបញ្ជូនកុមារីរងគ្រោះដោយការជួញដូរកម្លាំងពលកម្មចំនួន០៣នាក់ ទៅអង្គការAIM និងអង្គការARM ដើម្បីស្ដារនីតិសម្បទាបន្ត។
- **អង្គការសមាគមកុមាររីករាយ** បានទទួលកុមារារងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្មចំនួន១១នាក់ ស្នាក់នៅរយៈពេលខ្លី និងស្ដារនីតិសម្បទា។

**ឃ.៤-ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ** (ក្រុមការពារជនរងគ្រោះ)

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់សហគមន៍វិញ សរុបចំនួន០៤នាក់ (ស្រី០៣នាក់)។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

**១.១-សិក្ខាសាលា**

- **មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប** បានបើកសិក្ខាសាលា ស្ដីពីក្រុមប្រឹក្សាកុមារ សិទ្ធិកុមារ ការជួញដូរមនុស្ស ចំនួន០២លើក នៅស្រុកអង្គរជុំ អ្នកចូលរួមចំនួន៦៥នាក់ ស្រី០២នាក់។

១.២-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ៦៩លើក មានអ្នកចូលរួមសរុប១.៣៨៤នាក់ មានស្រី៣៩០នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន២៧លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន០៦លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន០៧លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន២៩លើក។ (ឧបសម្ព័ន្ធទី២)

## ២. ក្រៅប្រទេស

### ២.១-វគ្គបណ្តុះបណ្តាល

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលចំនួន០១រូប ទៅចូលរួមកិច្ចប្រជុំវគ្គបណ្តុះបណ្តាលកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យព្រំដែនលើកទី១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

### ២.២-សិក្ខាសាលា

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមសិក្ខាសាលាការលើកកម្ពស់ការការពារសិទ្ធពលករទេសន្តប្រវេសន៍៖ ស្តីអំពីដំណើរការចុះបញ្ជី និងអ្នកគ្មានឯកសារ ប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ីលតុន នាទីក្រុងបាងកក ប្រទេសថៃ។
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលចំនួន០១រូប ទៅចូលរួមសិក្ខាសាលា ស្តីពីគម្រោងនៅតំបន់អាស៊ីអាគ្នេយ៍ នៅកោះ PENANG ប្រទេសថៃ។

### ២.៣-សន្និសិទ្

- លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមសន្និសិទ្ធអន្តរជាតិរវាងកម្ពុជា-ថៃ៖ ការធ្វើទេសន្តប្រវេសន៍ការងារ និងអំពើជួញដូរមនុស្ស និងបានផ្តល់បទបង្ហាញអំពី ក្របខណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ពលករទេសន្តប្រវេសន៍កម្ពុជានៅក្នុងប្រទេសថៃ ប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ីលតុន នាទីក្រុងបាងកក ប្រទេសថៃ។

### ២.៤-ទស្សនៈកិច្ច

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមទស្សនកិច្ចសហគមន៍គ្រួសារទេសន្តប្រវេសន៍ខ្មែរនៅខេត្តសមុទ្រប្រាកាន ប្រទេសថៃ រៀបចំដោយអង្គការ LPN។
- ខេត្តបាត់ដំបង បានចូលរួមទស្សនៈកិច្ចអន្តរជាតិសម្រាប់ការពិភាក្សារវាងប្រទេសកម្ពុជា និងប្រទេសថៃ ស្តីពីបញ្ហាការជួញដូរមនុស្ស និងការចំណាកស្រុក នៅទីក្រុងបាងកក ប្រទេសថៃ។
- ខេត្តសៀមរាប លោកស្រីអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមសន្និសីទអន្តរជាតិ ស្តីពីការធ្វើទេសន្តប្រវេសន៍ពលករកម្ពុជា និងអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។
- ខេត្តកោះកុង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានទៅចូលរួមកិច្ចប្រជុំក្រុមលេខាធិការ នៃគណៈកម្មាធិការភូមភាគកម្ពុជា-ថៃលើកទី២១ រវាងភាគីកម្ពុជា យោធភូមិភាគ៣ និងភាគីថៃ កងបញ្ជាការការពារព្រំដែនច័ន្ទបុរីត្រាតលើកទី២១ នៅខេត្តច័ន្ទបូរី ដែលមានការអញ្ជើញចូលរួមពីអង្គភាព និងមន្ទីរពាក់ព័ន្ធក្នុងខេត្ត។ អង្គប្រជុំបានលើកឡើងនៅចំណុចរួមមួយ គឺរួមគ្នាបង្ការ ទប់ស្កាត់

និងបង្ក្រាបបទល្មើសការជួញដូរមនុស្សរវាងប្រទេសទាំងពីរ ដើម្បីដាក់ជូនគណៈកម្មាធិការថ្នាក់ភូមិភាគនៃប្រទេសទាំងពីរសម្រេច។

២.៩-ជាវាគ្មិន

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាជាសាធារណៈអំពីបទបញ្ញត្តិនានា និងគោលនយោបាយរវាងកម្ពុជា-ថៃ លើបញ្ហាការជួញដូរមនុស្ស និងពលករអន្តោប្រវេសន៍ នៅមូលនិធិ SEA Junction នាទីក្រុងបាងកក ប្រទេសថៃ។

## III. **ការសន្និដ្ឋានវាយតម្លៃ**

### **ក.ចំណុចខ្លាំង**

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### **ខ. ចំណុចខ្វះខាត ឬភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។

- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬ អង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ ដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយ

អ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅខែមិថុនា ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្តាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៥. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៨. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៩. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១០. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១១. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១២. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖

១៣. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៤. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៥. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៦. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ...............ឆ្នាំ..........សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ.............ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែឧសភា ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 34 លើក | 2,251 នាក់ | 1,195 នាក់ |
| 2 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ តាមរយៈការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត និងរដ្ឋបាលស្រុក | 207 លើក | 8,511 នាក់ | 5,547 នាក់ |
|  |  | វេទិកាសាធារណៈ តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 102 លើក | 3,363 នាក់ | 2,024 នាក់ |
| 3 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 663 លើក | 28,947 នាក់ | 10,445 នាក់ |
|  |  | ផ្សព្វផ្សាយ ស្តីពីការការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស និងបញ្ជ្រាបតាមកិច្ចប្រជុំ តាមរយៈការប្រារព្ធពិធីអបអរសាទរខួបលើកទី៦៩ ទិវកុមារអន្តរជាតិ។ | ក្រុមការងារថ្នាក់ស្រុក និងមន្ទីរអប់រំយុវជន និងកីឡា | 12 លើក | 1,888 នាក់ | 1,252 នាក់ |
| 4 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 6 លើក | 286 នាក់ | 141 នាក់ |
|  |  | ផ្សព្វផ្សាយតាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត | 137 លើក | 7,044 នាក់ | 3,450 នាក់ |
| 5 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 539 លើក | 56,299 នាក់ | 26,667 នាក់ |
|  |  | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 289 លើក | 10,957 នាក់ | 5,493 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តពោធិ៍សាត់ | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 594 លើក | 227,960 នាក់ | 130,472 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 107 លើក | 4,863 នាក់ | 2,602 នាក់ |
| 7 | ខេត្តព្រះសីហនុ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 65 នាក់ | 31 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ក្រុមការងារ គ.ខ.ប.ជខេត្ត | 2 លើក | 126 នាក់ | 73 នាក់ |
| 8 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាលក្រុង ស្រុក | 18 លើក | 847 នាក់ | 507 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការ ធ្វើអាជីវកម្មផ្លូវភេទស្ត្រី និងកុមារ ដល់សិស្សានុសិស្ស និងសហគមមូលដ្ឋាន។ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | 1 លើក | 5,831 នាក់ | 2,214 នាក់ |
| 9 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 473 លើក | 17,070 នាក់ | 8,433 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 499 លើក | 20,100 នាក់ | 10,196 នាក់ |
| 10 | ខេត្តរតនគិរី | ផ្សព្វផ្សាយ ទៅដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្ត ឲ្យអនុវត្តតាមច្បាប់ស្តីពីការងារ និងការបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់។ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | 13 លើក | 264 នាក់ | 118 នាក់ |
| 11 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 770 លើក | 50,211 នាក់ | 46,596 នាក់ |
| 12 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយតាមរយៈបញ្ជ្រាបគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់មន្ត្រីរាជការ កងកម្លាំង ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 2 លើក | 337 នាក់ | 176 នាក់ |
| 13 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 103 នាក់ | 62 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 14 | ខេត្តកំពង់ស្ពឺ | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ ដល់ ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 11 លើក | 1,685 នាក់ | 906 នាក់ |
| 15 | ខេត្តកែប | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈ គោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 23 លើក | 5,901 នាក់ | 2,929 នាក់ |
| 16 | ខេត្តព្រៃវែង | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសការពពោះជំនួស នៅស្រុកពារាំង និងស្រុកស៊ីធរកណ្តាល។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 300 នាក់ | 0 នាក់ |
| 17 | ខេត្តប៉ៃលិន | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈ គោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 16 លើក | 1,162 នាក់ | 702 នាក់ |

សកម្មភាពសរុបចំនួន: 4,523 លើក

មនុស្សសរុបចំនួន: 456,371 នាក់

ស្រីសរុបចំនួន : 262,231 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៦៩លើក)មនុស្សចំនួន១.៣៨៤នាក់ (ស្រី៣៩០នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន២៧លើក អ្នកចូលរួមសរុបចំនួន១៩៩នាក់ (ស្រី៩៣នាក់)<br>❖ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**<br>- ប្រជុំពិភាក្សាការផ្តល់យោបល់ លើអនុស្សរណៈនៃការយោគយល់គ្នារវាង ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈប្រជាមានិតចិន។<br>- ចូលរួមកិច្ចប្រជុំបច្ចេកទេសយេនឌ័រ (TWG-G) នៅទីស្តីការក្រសួងកិច្ចការនារី រាជធានីភ្នំពេញ។<br>- បានសហការជាមួយមូលនិធិ ឈៀន ឆាយ ដើម្បីមនុស្សធម៌ដែលជាដៃគូចុះពិនិត្យស្ថានភាពពលករខ្មែរ នៅក្រុមហ៊ុនសំណង់ធំមួយដែលប្រើប្រាស់ពលករជាង២ម៉ឺននាក់ និងមានបណ្តាញជាច្រើន ឈ្មោះថា JWS Construction Co. Ltd. នៅជាប់ខេត្តឈុនបូរី ប្រទេសថៃ។<br>- បានចូលរួមជាគណអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាលក្រិតវិជ្ជាជីវៈនគរបាល និងប្រកាសតាំងស៊ុបក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ប្រព្រឹត្តទៅនៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ។<br>- កិច្ចប្រជុំប្រចាំឆ្នាំលើកទី២ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន ស្តីពីភាពរីកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងផែនការសកម្មភាព ប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។<br>- ផ្តល់បទសម្ភាសន៍ស្តីពីភាពរីកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តការក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាពជាមួយទូរទស្សន៍ NICE TV ក្រសួងហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំ ពិភាក្សាពិនិត្យលទ្ធផលនិងការផ្តល់ពិន្ទុនៃការវាយតំម្លៃសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។<br>- បានដឹកនាំរៀបចំពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ ជ.ប.ជ.**មានអ្នកចូលរួមចំនួន **១៩៩**នាក់(ស្រី**៩៣**នាក់)។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ ពិភាក្សាពិគ្រោះយោលបល់ក្រុមប្រទេសបញ្ជូន ស្តីពីតួនាទីរបស់ប្រទេសបញ្ជូនដើម្បីពិភាក្សា (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) |

| | |
|---|---|
| | ពីបញ្ហារួម និងដំណោះស្រាយរួម នៅសណ្ឋាគារ សុខាល័យអង្គរ ខេត្តសៀមរាប។<br>❖ **ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត អគ្គលេខាធិការ គជ.ប.ជ.**<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ ពិភាក្សាលើការអនុវត្តសេចក្តីសំរេចលេខ៦៦/១៨ រៀបចំកិច្ចប្រជុំជាមួយគណៈ ២០១៨ខែមេសា ឆ្នាំ ២៦ចុះថ្ងៃទី ប្រតិភូចិននៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីមិទ្ទិញអបអរខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១មិថុនាខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារកម្ពុជា ឆ្នាំ២០១៨ ក្រោមអធិបតីភាព **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង **ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** នៅសាលមហោស្រពពិពណ៌កោះពេជ្រ ។<br>- ដឹកនាំ ពិនិត្យតាមដាន និងពិចារណាការងារប្រចាំថ្ងៃ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>**១.ក្រុមជំនួយកិច្ចការការបង្ការ ទប់ស្កាត់:**<br>- ស្រង់ព័ត៌មានតាមរយៈតេឡេក្រាម នូវរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានចុះផ្សព្វផ្សាយពីការបង្ការទប់ស្កាត់នៃភាពងាយរងគ្រោះ និងបទដ្ឋានច្បាប់នានាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅតាមសហគមន៍ សាលារៀន ដើម្បីជាបច្ច័យល្អដល់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>**២-ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- បានតាមដាន និងស្រង់ស្ថិតិជនរងគ្រោះតាមរយៈព័ត៌មានពីក្រសួង ស្ថាប័ន អង្គភាព និង NGO សរុបបានចំនួន ៤១នាក់ ស្រី១៩នាក់ ក្នុងនោះ បញ្ជូនត្រឡប់ពីប្រទេសដូចខាងក្រោម៖<br>•ប្រទេសថៃ០៦នាក់ ,ម៉ាឡេស៊ី២១នាក់(ស្រី១០នាក់) ,សសិង្ហបុរី ០១នាក់(ស្រី) ,ចិន០៩នាក់(ស្រី០៨នាក់) និងប្រទេសវៀតណាម០៩នាក់។<br>**៣-ក្រុមជំនួយកិច្ចការយុត្តិធម៌:** ឯកឧត្តឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង គ.ជ.ប.ជ បានដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំ៖<br>- នៅក្រសួងមហាផ្ទៃ ដឹកនាំដោយឯឧ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត តេង សាវង្ស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាមួយអគ្គពាក់ព័ន្ធ ក្នុងការរៀបចំ. គណៈកម្មការការពារ និងពិភាក្សាលើការចុះMOU រវាងក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខសាធារណៈចិន ។<br>- ពិភាក្សាជាមួយក្រុមការងារប្រតិភូចិន ពិភាក្សា សម្របសម្រួលលើកម្មវិធីនៃកិច្ចប្រជុំលើក ទី២ រវាងកម្ពុជាចិន ក្នុងការអនុវត្តកិច្ចព្រមព្រៀង និងការ-ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>- នៅក្រសួងមហាផ្ទៃរវាងភាគីកម្ពុជា-ចិន ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីចែងចែកក្រុមពិភាក្សារវាងកម្ពុជា-ចិន ក្រុមទី១ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍ **សុខ ផល** អគ្គនាយក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងក្រុមទី២ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ឆៃ ស៊ីណារិទ្ធ** អគ្គនាយករងពាគរបាលជាតិ ពិភាក្សាលើកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខ |

| | |
|---|---|
| | សាធារណៈចិន ។<br>- អង្គមីទិញអបអរសាទរ ខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨ ក្រោមការអញ្ជើញចូលរួមពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ប្រារព្ធនៅសាលមហោស្រពនៃមណ្ឌលសន្និបាត និងពិព័រកោះពេជ្រ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ។<br>- សិក្ខាសាលាស្តីពី កិច្ចពិភាក្សាជ្រើសរើសរឿងជោគជ័យជាលទ្ធផលនៃកម្មវិធី AAPTIP ក្រោមការគាំទ្រ និងសហការរបស់អគ្គស្នងការនគរបាលជាតិ និងក្រសួងយុត្តិធម៌ រៀបចំដោយអង្គការ AAPTIP នៅសណ្ឋាគារកាំបូឌីយ៉ាណា សមាភាពចូលរួមមាន អន្តរក្រសួង និងអង្គការដៃគូ ចំនួន ៣០ នាក់។<br>**<u>៤-ក្រុមជំនួយកិច្ចការអនុវត្តន៍ច្បាប់</u>**<br>- ទំនាក់ទំនង និងជំរុញក្រុមការងារយុត្តិធម៌ ដើម្បីស្រង់យកចំនួនតួលេខជម្រះក្តីពីក្រសួងយុត្តិធម៌។<br>**<u>៥-ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:</u>**លោកជំទាវ រ៉ែន សិរីលក្ខិណា និងលោក អ៊ិន មាន ក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖<br>- បានចូលរួមកិច្ចប្រជុំ ស្តីពី បច្ចុប្បន្នភាពការងារ ដើម្បីស្តាប់នូវរបាយការណ៍វិវឌ្ឍន៍ថ្មីៗ និងបញ្ហាប្រឈម ក្នុងកំឡុងពេលអនុវត្តការងារពីអ្នកចូលរួម និងពិភាក្សាលើការងារជាអទិភាពត្រូវអនុវត្តបន្ត នៅសាលប្រជុំក្រសួងកិច្ចការនារី។<br>- បានដឹកនាំក្រុមការងារទៅទទួលគណៈប្រតិភូចិន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។<br>- បានធ្វើការពិនិត្យ និងកែតម្រូវ រូបភាព ខ្លឹមសារ និងអក្ខរាវិរុទ្ធ មួយចំនួននៅលើឯកសារពង្រាងរបាយការណ៍បូកសរុបលទ្ធផល ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០១៧ និងទិសដៅអនុវត្តឆ្នាំ ២០១៨ មុននឹងធ្វើការបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ។<br>- បានធ្វើការប្រជុំផ្ទៃក្នុងទាក់ទងនឹងតារាងផែនការសកម្មភាពសម្រាប់ការអនុវត្តឆ្នាំ ២០១៨ ក្រោមការដឹកនាំរបស់លោកជំទាវ រ៉ែន សិរីលក្ខិណា។<br>**<u>៦-ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:</u>**<br>- បានស្នើសុំកិច្ចសហការផ្តល់របាយការណ៍ ស្តីពីលទ្ធផលជួយសង្គ្រោះ និងអន្តរាគមន៍ពលរដ្ឋខ្មែរពីបរទេសរបស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិប្រចាំខែមេសា ឆ្នាំ២១០៨ ជាលទ្ធផលក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានទទួលពីមន្ត្រីនាយកដ្ឋានច្បាប់ និងកិច្ចការកុងសុល តាមរយៈតេឡេក្រាមហើយ តែមិនទាន់ចុះហត្ថលេខាជាផ្លូវការនៅឡើយ។<br>- បានស្រាវជ្រាវតាមប្រព័ន្ធទំនាក់ទំនងសង្គម (Telegram, Facebook) ជាលទ្ធផល៖ នៅខែមិថុនាខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបញ្ជូនស្ត្រីខ្មែរទៅធ្វើការតាមផ្ទះនៅប្រទេសម៉ាឡេស៊ីឡើងវិញចំនួន ៣០០នាក់ក្រោយពីការផ្អាក ការបញ្ជូនស្ត្រីបម្រើតាមផ្ទះ ទៅប្រទេសម៉ាឡេស៊ី តាំងពីខែតុលា ឆ្នាំ២០១១ បន្ទាប់ពីមានការរំលោភបំពាន រហូតបណ្តាលឲ្យស្ត្រីខ្មែរស្លាប់ជាច្រើននាក់ក្នុងពេលបំពេញការងារនៅទីនោះ ។ យោងតាមគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដដែលបានបញ្ជាក់ថា ចាប់តាំងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីមកដល់បច្ចុប្បន្នមានចំនួនជាង ៤៨ម៉ឺននាក់ ក្នុងនោះមានស្ត្រីជាង ៤០ម៉ឺននាក់ ។ រីឯចំនួនស្ត្រីខ្មែរធ្វើការ |

| | |
|---|---|
| | តាមផ្ទះនៅប្រទេសម៉ាឡេស៊ីមានជិត ៣៤ម៉ឺននាក់ ។<br>- លោកឧត្តមសេនីយ៍ត្រី កែវ ផល្លា បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីការឧបត្ថមគាំទ្រជួយជំលៀសពលរដ្ឋរបស់ខ្លួន ដែលរងគ្រោះនូវគ្រោះមហន្តរាយក្នុងប្រទេសដែលមានវិបត្តិក្រោមការរៀបចំឡើងដោយអង្គការ IOM នៅសណ្ឋាគារភ្នំពេញ ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** | បានសម្របសម្រួលចំនួន**០៦**លើក អ្នកចូលរួមចំនួន**២១៨**នាក់ ស្រី**១០៣**នាក់៖<br>- បានចាត់បញ្ជូនមន្រ្តីចំនួន០៧រូប ចំនួន០៤លើក ដើម្បីចូលរួម៖<br>• មន្រ្តីចំនួន០២រូបចូលជាគ្រូឧទ្ទេសចំនួន០៣លើក ស្តីពីការសង្គ្រោះចិត្តសាស្រ្តបឋម និងសមាហរណកម្មចិត្តសង្គមចំនួន០៧វគ្គ នៅខេត្តបន្ទាយមានជ័យ និងសៀមរាប រៀបចំដោយអង្គការIOM និងស្តីពីការពង្រឹងសមត្ថភាពដល់មន្រ្តីផ្តល់សេវាសង្គមកិច្ច នៅមជ្ឈមណ្ឌលICF(ភ្នំពេញ) រៀបចំដោយអង្គការ HAGAR មានអ្នកចូលរួមសរុបរួមចំនួន២១៨នាក់ ស្រី១០៣នាក់។<br>• មន្រ្តី០៥រូបចូលរួមវគ្គបណ្តុះបណ្តាលចំនួន០១លើក ស្តីពីបច្ចេកទេសនៃការសម្ភាស ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការជួយសម្របសម្រួលដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា រៀបចំដោយអង្គការIOM។<br>- បានជួបប្រជុំជាមួយអង្គការដៃគូពិភាក្សាលើគម្រោងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ជាលើកទី៥ អ្នកចូលរួមចំនួន១០នាក់ ស្រី០៣នាក់។<br>- បានចូលរួមកិច្ចប្រជុំចំនួន**០២**លើក៖<br>• កិច្ចប្រជុំពាក់ព័ន្ធសំណើរចុះMOUs របស់អង្គការIJM និងអង្គការរតនៈជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>• កិច្ចប្រជុំពីភាពរីកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីប្រចាំឆ្នាំលើកទី២ កម្ពុជា-ចិន កិច្ចសហប្រតិបត្តិការក្នុងការបង្ការ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| **អគ្គនាយកដ្ឋាន អន្តោប្រវេសន៍** | ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **សុខ ផល** អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖<br>- បានអញ្ជើញចូលរួមក្នុងឱកាស **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** អនុញ្ញាតិឲ្យ៖<br>• ឯកឧត្តម **DMITRI TSVETKOV** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសម នៅសាលទទួលភ្ញៀវអន្តរជាតិ ទីស្តីការក្រសួងមហាផ្ទៃ។<br>• ឯកឧត្តម **CHEN SHIGU** អគ្គនាយករងក្រសួងសន្តិសុខសាធារណរដ្ឋចិន និងជាប្រធានក្រុមការងារខមមីតចិន ចូលសម្តែងការគួរសម នៅសាលទទួលភ្ញៀវអន្តរជាតិ ទីស្តីការក្រសួងមហាផ្ទៃ។<br>• ឯកឧត្តម **ZHAO KEZHI** សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងជំនួបពិភាក្សាផ្លូវការរវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន នៅសាលទទួលភ្ញៀវអន្តរជាតិ ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទវគ្គបណ្តុះបណ្តាលកម្រិតបឋមវិជ្ជាជីវៈនគរបាល និងប្រកាសតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីនគរបាលកម្ពុជា ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅបណ្ឌិតសភានគរបាលកម្ពុជា។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការងារចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ **សម្តេចក្រឡាហោម ឧបនាយក** |

<table>
<tr><td></td><td>រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំក្រុមពិភាក្សាការងារជំនាញរវាងភាគីទាំងពីរ កម្ពុជា និងចិន ស្តីពីការគ្រប់គ្រងព្រំដែន ការតាមចាប់ជនសង្ស័យ កិច្ចសហប្រតិបត្តិការ ការពារសុវត្ថិភាពវិថីមួយផ្លូវសូត្រមួយ ការប្រយុទ្ធប្រឆាំងបទល្មើស ការប្រយុទ្ធប្រឆាំងជនបរទេសប្រព្រឹត្តបទល្មើស ការជួញដូរមនុស្ស ការឆបោកតាមទូរគមនាគមន៍ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចការនគរបាលនៅតាមមូលដ្ឋាន។<br>- បានទទួលជួបពិភាក្សាការងារជាមួយលោកស្រី DOMICA POTTIE ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំនៅទីក្រុងបាងកក និងលោកស្រី ALLISON STWARD ភារធារីស្ថានទូតកាណាដាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។</td></tr>
<tr><td colspan="2">លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន២៩លើក អ្នកចូលរួមសរុបចំនួន៩៣៧នាក់ (ស្រី២៩៤នាក់)</td></tr>
<tr><td>ខេត្តកណ្តាល</td><td>- បានរៀបចំកិច្ចប្រជុំចំនួន០៧លើក អ្នកចូលរួមចំនួន១៤៩នាក់ ស្រី១០៧នាក់៖<br>• ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែឧសភាចំនួន០៦លើក អ្នកចូលរួមចំនួន១២១នាក់ ស្រី៩០នាក់<br>• គណៈកម្មាធិការគ.ខ.ប.ជ និងលេខាធិការដ្ឋានខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែឧសភា អ្នកចូលរួមចំនួន២៨នាក់ ស្រី១៧នាក់។</td></tr>
<tr><td>ខេត្តសៀមរាប</td><td>បានសម្របសម្រួលចំនួន០៨លើក អ្នកចូលរួមចំនួន១២៨នាក់ ស្រី២៩នាក់៖<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ និងចូលរួមកិច្ចប្រជុំចំនួន០៥លើក អ្នកចូលរួមចំនួន៤៨នាក់ ស្រី២១នាក់៖<br>• កិច្ចប្រជុំប្រចាំខែឧសភា អ្នកចូលរួមចំនួន៤៨នាក់ ស្រី២១នាក់ នៅបន្ទប់ប្រជុំសាលាខេត្ត<br>• ជួបពិភាក្សាការងារជាមួយអង្គការអាដហុក ស្តីពីការផ្តល់សេវាកម្មលើលិខិតឆ្លងដែនជូនពលករ<br>• ចូលរួមពិធីសំណេះសំណាល និងអាហារសាមគ្គីជាមួយអាជ្ញាធរឃុំ សង្កាត់គោលដៅគម្រោងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ទប់ស្កាត់ពលកម្មកុមារ និងអំពើជួញដូរមនុស្ស រៀបចំដោយអង្គការដើម្បីភាពញញឹមនៃកុមារ។<br>• ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសនៃប្រទេសបញ្ចូន (កម្ពុជា ឡាវ និងភូមា) នៅសណ្ឋាគារសុខាល័យអង្គរ។<br>• ចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការងារចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។<br>- ស្នងការដ្ឋាននគរបាលខេត្ត៖<br>• ចូលរួមវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ អ្នកចូលរួមចំនួន២០នាក់ ស្រី០៥នាក់<br>• ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសសម្ភាសន៍ និងកំណត់អត្តសញ្ញាណជនរងគ្រោះអំពើជួញដូរមនុស្ស សហការជាមួយអង្គការទស្សនពិភពលោក អ្នកចូលរួមចំនួន៦០នាក់ ស្រី០៣នាក់ នៅស្នងការដ្ឋាននគរបាលខេត្ត<br>• រៀបចំកិច្ចប្រជុំប្រចាំខែឧសភា របស់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ក្រុង ស្រុក។</td></tr>
<tr><td>ខេត្តព្រៃវែង</td><td>- លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។</td></tr>
</table>

| | |
|---|---|
| ខេត្តកែប | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។ |
| ខេត្តបាត់ដំបង | - បានចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។ |
| ខេត្តកំពង់ចាម | - បានចូលរួមកិច្ចប្រជុំ ស្តីពីនីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ |
| ខេត្តប៉ៃលិន | - បានចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។ |
| ខេត្តកំពង់ធំ | - បានចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានជួបសម្ភាសន៍ជាមួយគម្រោងអូស្ត្រាលីអាស៊ីប្រឆាំងការជួញដូរមនុស្ស (AAPTIP) ដើម្បីស្វែងយល់ពីភាពរីកចម្រើន និងបញ្ហាប្រឈមនានា នៃការអនុវត្តផែនការសកម្មភាពយេនឌ័រ និងក្រុមប្រតិបត្តិយេនឌ័រ ដែលបានអនុវត្តកន្លងមកនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ។ |
| ខេត្តព្រះសីហនុ | លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន០២លើក អ្នកចូលរួមចំនួន១៤នាក់ ស្រី០៧នាក់៖<br>• កិច្ចប្រជុំពិភាក្សាជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) ស្តីពីការស្វែងយល់អំពីស្ថានភាពនៃការរំលោភបំពាន សកម្មភាពជួញដូរផ្លូវភេទ អ្នកចូលរួមចំនួន០៥នាក់ ស្រី០៣នាក់។<br>• កិច្ចប្រជុំពិភាក្សាជាមួយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ យូនីសេហ្វ(UNICEF) លើបញ្ហាសុវត្ថិភាពកុមារ និងការរីកចម្រើននៅថ្ងៃអនាគត់ អ្នកចូលរួមចំនួន០៩នាក់ ស្រី០៤នាក់។ |
| ខេត្តតាកែវ | - លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួម៖<br>• កិច្ចប្រជុំចំនួន០៤លើក ស្តីពីការពង្រឹងការងារជួញដូរមនុស្ស និងការធ្វើចំណាកស្រុក អ្នកចូលរួមចំនួន៦៤៦នាក់ ស្រី១៥១នាក់។<br>• ពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ (S) ទីស្តីការក្រសួងមហាផ្ទៃ។ |